**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ......០៥៣......សខល

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១០..

# ប្រកាស
# ស្តីពី
# ការកែសម្រួលភារកិច្ចថ្នាក់ដឹកនាំក្រសួងសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស-រកម-០១៩៦-០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ២០អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/កត ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៦ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០

-យោងប្រកាសលេខ ៧០៤ ស.ខ.ល ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ របស់ក្រសួងសុខាភិបាល

-យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំក្រសួង នាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០

-យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច ៖

**ប្រការ ១.-**

ត្រូវបានកែសម្រួលភារកិច្ច ជូន **ឯកឧត្តម រដ្ឋលេខាធិការ** ដូចខាងក្រោម៖

**១-ឯកឧត្តម អេង ហួត**

ជួយឯកឧត្តមរដ្ឋមន្ត្រី លើការងារ ៖

-ដឹកនាំគម្រោងទ្រទ្រង់វិស័យសុខាភិបាល ( HSSP) និងភ្នាក់ងារប្រតិបត្តិការពិសេស (SOA)

-ត្រួតពិនិត្យជំងឺឆ្លង-ចត្តាឡីស័ក

-សុខភាពមាតា និងទារក ( MCH )

-សុខភាពផ្លូវចិត្ត

-បណ្តុះបណ្តាលបន្ត ( ផ្នែកការពារជំងឺ)

-ការងារអាស៊ាន

**២-ឯកឧត្តម តែ គុយស៊ាង**

ជួយឯកឧត្តមរដ្ឋមន្ត្រី លើការងារ ៖

-គ្រប់គ្រងគ្រោះមហន្តរាយ

-ការងាររដ្ឋបាល

-ការងារគ្រប់គ្រងបុគ្គលិក

-ការងារវិមជ្ឈការ-វិសហមជ្ឈការ

**ប្រការ ២.-** ត្រូវបានបែងចែកភារកិច្ចជូន **ឯកឧត្តម ធា គ្រួយ** រដ្ឋលេខាធិការ

ជួយឯកឧត្តមរដ្ឋមន្ត្រី លើការងារ៖

-លើកកម្ពស់គុណភាព

-បណ្តុះបណ្តាលបន្តផ្នែកថែទាំ និងព្យាបាល

-ការងារអធិការកិច្ច

-ការងារបណ្តុះបណ្តាលមូលដ្ឋាន

-ការងារសម្របសម្រួលជាមួយ គណៈគ្រូពេទ្យ-គណៈគិលានុបដ្ឋាក ។

**ប្រការ ៣.-** ភារកិច្ចរបស់ឯកឧត្តម ហេង តៃគ្រី ឯកឧត្តម អ៊ឹង ភិរុន ឯកឧត្តម សុខ ផេង លោកជំទាវ អ៊ុក ម៉ុណ្ណា និង ឯកឧត្តម ជូ យិនស៊ីម ដែលមានចែងក្នុងប្រកាសលេខ ៧០៤ ស.ខ.ល ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ត្រូវរក្សាទុកដដែល ។

**ប្រការ ៤.-** ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់អង្គភាពសុខាភិបាលថ្នាក់កណ្តាល រាជធានី និង ខេត្ត ព្រមទាំង ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

មំ_ប៊ុនហេង

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "

-ដូចមានចែងក្នុងប្រការ ៤ " ដើម្បីអនុវត្ត "

-សាមីខ្លួន

-ឯកសារ-កាលប្បវត្តិ